# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៤៧៩..សសរ

## សេចក្តីសំរេច

## ស្តីពី

## ការផ្លាស់ប្តូរសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា

~~~~~~~~~~~~~~~

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១០៥/ ០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងអនុស្សារណៈយោគយល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤
- យោងអនុស្សារណៈ ស្តីពីការរៀបចំចាត់ចែងទាក់ទងនឹងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៧
- យោងសេចក្តីសំរេចលេខ ២៥ សសរ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា
~~~~~~~~~~~~~~~

- យោងសេចក្តីសំរេចលេខ ៥៣ សសរ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកែសម្រួលសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា
- យោងសេចក្តីសំរេចលេខ ១០ សសរ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ។

## សំរេច

**ប្រការ១:** ត្រូវបានតែងតាំងលោក **ង៉ែត សយ** អភិបាលរងខេត្តបាត់ដំបង ជាសមាជិកក្រុមពិគ្រោះយោបល់នៃក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា និងជាជនបង្គោលសំរាប់ខេត្តបាត់ដំបង ជំនួសលោក **អ៊ុក ខន** ។

**ប្រការ២:** រាល់បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

**ស ខេង**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា
- ដូចប្រការ១
- ឯកសារ-កាលប្បវត្តិ